hepatitis australia



Images used are stock photos and the associated messaging may not represent the personal situation, views or beliefs of the people in the images.

# ការណែនាំអំពីជំងឺរលាកថ្លើមប្រភេទ B

## ការធ្វើតេស្ត ការព្យាបាល និងការរក្សាសុខភាពល្អ

## អំពីធនធាននេះ

ការណែនាំនេះ គឺដើម្បីជួយ អ្នកឱ្យយល់ដឹងអំពីដំណើរការចាប់ពីការធ្វើតេស្តរកមើលជំងឺរលាកថ្លើមប្រភេទ B (ជញឹកញាប់គេហៅថាជំងឺរលាកថ្លើមប្រភេទ B) ដល់ការរស់នៅបានល្អប្រសើរពីជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ (ពេញមួយជីវិត)។ ការណែនាំនេះ ត្រូវបានរៀបចំឡើងដើម្បីជួយប្រជាពលរដ្ឋដែលមានហានិភ័យឬបច្ចុប្បន្ន ត្រូវបានធ្វើវិភាគរោគវិនិច្ឆ័យឃើញមានជំងឺរលាកថ្លើមប្រភេទ B ។

ព័ត៌មានដែលបានផ្តល់ជូននៅក្នុងការណែនាំនេះ គឺជាព័ត៌មានទូទៅតែប៉ុណ្ណោះ ហើយមិនមានបំណងជំនួសឱ្យការផ្តល់ដំបូន្មានខាងវេជ្ជសាស្ត្រឡើយ។ Hepatitis Australia ជម្រុញលើកទឹកចិត្តឱ្យអ្នកអានទាំងអស់ ស្វែងរក ដំបូន្មានខាងវេជ្ជសាស្ត្រឯករាជ្យ មុនពេលធ្វើការសម្រេចចិត្តណាមួយដោយផ្អែកលើព័ត៌មានដែលបានផ្តល់ជូន។




## លទ្ធផលតេស្ត

**អវិជ្ជមាន**
**មានភាពស៊ាំនឹងជំងឺ**

អ្នក បានចាក់ថ្នាំបង្ការរោគ មានភាពស៊ាំនឹងជំងឺ និង មិនអាចឆ្លងជំងឺរលាកថ្លើម ប្រភេទ B

**អវិជ្ជមាន**
**មិនស៊ាំនឹងជំងឺ**

ទទួលការចាក់ថ្នាំបង្ការរោគ

**ជាស្រឡះ**
**មានភាពស៊ាំនឹងជំងឺ**

ធ្វើតេស្តក្រុមគ្រួសារ និងមនុស្ស ដែលរស់នៅជាមួយ អ្នក

**វិជ្ជមាន**

ធ្វើតេស្តថ្លើម

ធ្វើតេស្តក្រុមគ្រួសារ ដៃគូ និង មនុស្សដែលរស់នៅជាមួយ អ្នក

សូមទៅជួបគ្រូពេទ្យ រៀងរាល់ 6 ទៅ 12 ខែម្តង

បរិភោគអាហារដែលមាន សុខភាពល្អ ហាត់ប្រាណ និង កាត់បន្ថយការប្រើប្រាស់ គ្រឿងស្រវឹង និងការជក់បារី

ទទួលការព្យាបាល បើសិន ចាំបាច់

# 1 ត្រូវការគិតមើលបើសិន អ្នកគួរ ធ្វើតេស្តរកមើលជំងឺរលាកថ្លើមប្រភេទ B

## ក្រុមមនុស្សខាងក្រោមនេះ គួរធ្វើតេស្តរកមើលជំងឺរលាកថ្លើមប្រភេទ B:[1]

- ក្រុមគ្រួសារ ដៃគូ និងមនុស្សដែលរស់នៅជាមួយអ្នកណាម្នាក់ដែលមានផ្ទុកជំងឺរលាកថ្លើមប្រភេទ B
- មនុស្សកើតនៅក្នុងតំបន់មួយនៃតំបន់ដែលមានពណ៌ទឹកក្រូចនៅលើផែនទីខាងក្រោម[2]
- ជនជាតិដើម ឬអ្នកកោះ Torres Strait
- ស្ត្រីមានផ្ទៃពោះ
- ទារក និងកុមារដែលមានអាយុលើសពី 9 ខែ កើតពីម្តាយដែលមានជំងឺរលាកថ្លើមប្រភេទ B
- មនុស្សដែលនឹងត្រូវទទួលការព្យាបាល ប្រើថ្នាំគីមី ការព្យាបាលភាពស៊ាំនឹងជំងឺចុះខ្សោយ ឬការលាងឈាម
- អ្នកជំនាញផ្នែកសុខភាពដែលអនុវត្តនីតិវិធីដែលប្រើដៃពាក់ស្រោមដៃអាចប៉ះពាល់ឧបករណ៍មុត
- សមាជិកនៃកងកម្លាំងប្រដាប់អាវុធ
- អ្នកដែលមានផ្ទុកមេរោគ HIV និង/ឬ ជំងឺរលាកថ្លើមប្រភេទ C
- អ្នកដែលមានដៃគូរួមភេទច្រើននាក់ ដែលមិនបានចាក់ថ្នាំបង្ការរោគ
- អ្នកដែលធ្លាប់ចាក់ថ្នាំញៀន
- អ្នកដែលធ្លាប់ជាប់ពន្ធនាគារ
- បុរសដែលរួមភេទជាមួយបុរស
- អ្នករកស៊ីផ្លូវភេទ
- មនុស្សមួយចំនួនដែលមានសញ្ញា ឬរោគសញ្ញានៃការខូចថ្លើម
- អ្នកដែលមានប្រវត្តិក្រុមគ្រួសារមានជំងឺថ្លើម។

## តំបន់នានាដែលមានការរាតត្បាតជំងឺរលាកថ្លើមប្រភេទ B ពីកម្រិតមធ្យម ទៅខ្ពស់





## 2 សូមស្នើសុំគ្រូពេទ្យរបស់អ្នកដើម្បីធ្វើតេស្តរកមើលជំងឺរលាកថ្លើមប្រភេទ B

ការធ្វើតេស្តរកមើលជំងឺរលាកថ្លើមប្រភេទ B មិនមែនជាផ្នែកនៃការធ្វើតេស្តឈាមធម្មតាទេ។ បើសិន អ្នកមិនដឹងថា អ្នកបានធ្វើតេស្តពីមុនមកនោះ អ្នកត្រូវសួរគ្រូពេទ្យរបស់អ្នក។ គ្រូពេទ្យ GP របស់អ្នក នឹងចាំបាច់ត្រូវធ្វើតេស្តឈាម ដែលនឹងប្រាប់ពួកគេថាតើ អ្នកមានជំងឺរលាកថ្លើមប្រភេទ B ឬអត់ ហើយបើមិនមានទេ ថាតើ អ្នកមានភាពស៊ាំនឹងជំងឺរលាកថ្លើមប្រភេទ B ឬទេ។

នៅពេលដែល ការធ្វើតេស្តរកមើលជំងឺរលាកថ្លើមប្រភេទ B មួយចំនួនធំអាចមានភាពច្របូកច្របល់ គ្រូពេទ្យ GP របស់អ្នកអាចពេញចិត្តដែលត្រូវបានចង្អុលបង្ហាញទៅនឹងជំនួយក្នុងការសម្រេចចិត្តដែលងាយស្រួលនេះ ដែលបានបង្កើតឡើងដោយ ASHM:
https://ashm.org.au/products/product/1976963402

### សេវាកម្មបកប្រែភាសា

បើសិន អ្នកត្រូវការជំនួយដើម្បីប្រាស្រ័យទាក់ទងជាមួយគ្រូពេទ្យរបស់អ្នក អ្នកអាចមានអ្នកបកប្រែភាសាម្នាក់មកកាន់ទីណាត់ជួបរបស់អ្នក ឬបកប្រែ តាមទូរស័ព្ទ។ នេះគឺជាសេវាកម្មឥតគិតថ្លៃ តាមរយៈ TIS (សេវាកម្មបកប្រែភាសា សរសេរ និងនិយាយ) National។.[3] អ្នកគួរប្រាប់គ្លីនិករបស់គ្រូពេទ្យថា អ្នកត្រូវការអ្នកបកប្រែភាសាម្នាក់ នៅពេល អ្នកធ្វើការណាត់ជួប។

ខណៈពេលក្រុមគ្រួសារ និងមិត្តភក្តិអាចជាអ្នកគាំទ្រល្អនៅពេល អ្នកទៅជួបគ្រូពេទ្យ យើងខ្ញុំសូមណែនាំ អ្នកទទួលអ្នកបកប្រែភាសាដែលមានវិជ្ជាជីវៈ ដើម្បីជួយ អ្នកទាក់ទងជាមួយគ្រូពេទ្យរបស់អ្នក។ ការសម្រេចចិត្តលើសុខភាពអាចជាការលំបាកក្នុងការធ្វើ ហើយវាមានសារៈសំខាន់ណាស់ដែល អ្នកអាចយល់ដឹងអំពីអ្វីគ្រប់យ៉ាង ដើម្បីជួយ អ្នកធ្វើការសម្រេចចិត្តត្រឹមត្រូវ។ អ្នកបកប្រែភាសារបស់ TIS National គឺជាអ្នកជំនាញដែលបានបណ្តុះបណ្តាល ហើយមានបទពិសោធន៍ច្រើនក្នុងការប្រែព័ត៌មានស្មុគស្មាញ។

**វិបសៃថ៍៖www.tisnational.gov.au**
**ហៅទូរស័ព្ទលេខ 131 450 ដើម្បីទទួលបានអ្នកបកប្រែភាសាតាមទូរស័ព្ទដោយឥតគិតថ្លៃ ដោយអស់ថ្លៃហៅទូរស័ព្ទដូចក្នុងតំបន់។.**

# 3 ទទួលលទ្ធផលតេស្តរបស់អ្នក។.

**ការធ្វើតេស្តរកមើលជំងឺរលាកថ្លើមប្រភេទ B អាចបង្ហាញលទ្ធផលមួយ ក្នុងចំណោមលទ្ធផល បួនផ្សេងៗគ្នា។**

| | | | |
|---|---|---|---|
| 1 | អវិជ្ជមាន<br>មានភាពស៊ាំនឹងជំងឺ (បានចាក់ថ្នាំបង្ការរោគ) | អ្នកបានចាក់ថ្នាំបង្ការរោគប្រឆាំងនឹងជំងឺរលាកថ្លើមប្រភេទ B ហើយ អ្នកមិនអាចឆ្លងជំងឺនេះទេ។ | ***អ្នក មិនចាំបាច់ ធ្វើតាម ជំហានបន្ទាប់ទេ***<br> |
| 2 | អវិជ្ជមាន<br>មិនស៊ាំនឹងជំងឺ | អ្នកមិនដែលមានជំងឺរលាកថ្លើមប្រភេទ B ហើយមិនដែលបានចាក់ថ្នាំបង្ការឡើយ។ អ្នកអាចសាកសួរគ្រូពេទ្យរបស់អ្នកអំពីការចាក់ថ្នាំបង្ការ ដូច្នេះ អ្នកមិនអាចឆ្លងជំងឺរលាកថ្លើមប្រភេទ B នាពេលអនាគតឡើយ។ | |
| 3 | ជាស្រឡះ<br>មានភាពស៊ាំនឹងជំងឺ | អ្នកធ្លាប់មានជំងឺរលាកថ្លើមប្រភេទ B កាលពីមុន ប៉ុន្តែរាងកាយរបស់អ្នកបានឱ្យវាជាស្រឡះដោយធម្មជាតិ។ អ្នកមិនមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃទេ។អ្នកគួរគិតពិចារណាអំពីការប្រាប់ក្រុមគ្រួសារ ដៃគូរបស់អ្នក និងមនុស្សដែលរស់នៅជាមួយ អ្នក ដើម្បីឱ្យពួកគេអាចធ្វើតេស្ត។ គ្រូពេទ្យរបស់អ្នកអាចទាក់ទងមកពួកគេដោយមិនបញ្ចេញឈ្មោះ បើសិន អ្នកមានការព្រួយបារម្ភអំពីការប្រាប់ពួកគេ។<br><br>វាមានសារៈសំខាន់ណាស់ ដើម្បីកត់សម្គាល់ថា អ្នកដែលមានជំងឺរលាកថ្លើមប្រភេទ B ដែលបានជាស្រឡះហើយ អាចកើតកញ្ជ្រោលឡើងខ្លាំងនៅពេលព្យាបាល ប្រើថ្នាំគីមី ឬ ព្យាបាល ដោយប្រព័ន្ធភាពស៊ាំនឹងជំងឺចុះខ្សោយ។ អ្នកអាចត្រូវការការព្យាបាលបន្ថែមសម្រាប់ជំងឺរលាកថ្លើមប្រភេទ B បើសិន អ្នកប្រើថ្នាំទាំងនេះ។ | |
| 4 | ជំងឺរលាកថ្លើមប្រភេទ B វិជ្ជមាន | វាទំនងថា អ្នកមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ។ ជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃជាជំងឺកើតមានពេញមួយជីវិត ប៉ុន្តែមានកិច្ចការទាំងឡាយដែល អ្នកអាចធ្វើបានដើម្បីជួយ អ្នករក្សាសុខភាពល្អ។<br><br>មិនមិនបានព្យាបាលទេ ជំងឺរលាកថ្លើមប្រភេទ B អាចបំផ្លាញថ្លើមរបស់អ្នក និងបណ្ដាលឱ្យមានជំងឺក្រិនថ្លើម (ស្នាមក្រិនថ្លើមធ្ងន់ធ្ងរ), ជំងឺថ្លើមជំងឺមហារីកថ្លើម និងជំងឺខ្សោយថ្លើម។ មិនមាន<br><br>ការព្យាបាលសម្រាប់ជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃទេ ប៉ុន្តែបើសិនវាកំពុងធ្វើឱ្យខូចថ្លើមរបស់អ្នក មានវិធីព្យាបាលដែល អ្នកអាចប្រើដើម្បីគ្រប់គ្រង និង<br><br>កាត់បន្ថយផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់ពីវីរុសនេះ។ បើសិនអ្នកបានប៉ះពាល់នឹងវីរុសនាពេលថ្មីៗនេះ អ្នកនឹងចាំបាច់ត្រូវការធ្វើតេស្តមួយផ្សេងទៀត ក្នុងរយៈពេលប្រាំមួយខែដើម្បីកំណត់ថាតើ អ្នកមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃឬអត់។ | ***ធ្វើតាម ជំហានបន្ទាប់***<br> |



## 4 ធ្វើតេស្តថ្លើម

គ្រូពេទ្យរបស់អ្នក នឹងត្រូវការធ្វើតេស្តមួយចំនួន ដើម្បីពិនិត្យមើលថាតើថ្លើមរបស់អ្នកដំណើរការយ៉ាងដូចម្តេច។ ការណ៍នេះ ភាគច្រើនទំនងជាមានការធ្វើតេស្តឈាមមួយចំនួន និងការថតអេកូ (ultrasound) ឬឧបករណ៍ស្កេនថ្លើម Fibroscan® (ការធ្វើតេស្តដោយគ្មានការឈឺចាប់ដែលប្រើរំញ័រដើម្បីពិនិត្យមើលថាតើថ្លើមរឹងប៉ុណ្ណា)។[4]

ហើយនេះនឹងជួយគ្រូពេទ្យរបស់អ្នកឱ្យបានយល់ដឹងពីរបៀបដែលជំងឺរលាកថ្លើមប្រភេទ B កំពុងមានផលប៉ះពាល់ដល់ អ្នក និងថាតអ្នកត្រូវការចាប់ផ្តើមការព្យាបាលឬអត់។

## 5 ធ្វើតេស្តក្រុមគ្រួសារ ដៃគូ និងមនុស្សដែលរស់នៅជាមួយ អ្នក

ជំងឺរលាកថ្លើមប្រភេទ B ត្រូវបានចម្លងជាទូទៅច្រើនបំផុតតាមកំណើតកូន។ វាក៏អាចចម្លងតាមឈាមទៅឈាមផងដែរ ការប៉ះពាល់ ឬការរួមភេទដោយគ្មានស្រោមអនាម័យ។ អ្នកត្រូវគិតពិចារណាអំពីការប្រាប់ក្រុមគ្រួសារ ដៃគូរបស់អ្នក និងមនុស្សដែលរស់នៅជាមួយ អ្នកថា អ្នកមានជំងឺរលាកថ្លើមប្រភេទ B ដូច្នេះពួកគេអាចធ្វើតេស្ត និងចាក់ថ្នាំបង្ការរោគ។

ការមានជំងឺរលាកថ្លើមប្រភេទ B មិនមានន័យថា អ្នកមិនអាចមានកូន ឬធ្វើអ្វីៗដូចជាការទទួលទានអាហាររួមគ្នាជាមួយគ្រួសារ និងមិត្តភក្តិរបស់អ្នកទេ។ វិធីល្អបំផុតដែលក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកអាចការពារខ្លួនពួកគេពីការឆ្លងជំងឺរលាកថ្លើមប្រភេទ B គឺតាមរយៈការចាក់ថ្នាំបង្ការរោគ។

គ្រូពេទ្យរបស់អ្នកអាចទាក់ទងពួកមកគេដោយមិនបញ្ចេញឈ្មោះ បើសិន អ្នកមានការព្រួយបារម្ភអំពីការប្រាប់ពួកគេ។ សម្រាប់ព័ត៌មានបន្ថែមអំពីការសម្ងាត់ និង ការលាតត្រដាង សូមចូលមើលវិបសៃថ៍ www.hepatitisaustralia.com/Listing/Category/your-rights-and-responsibilities

### អ្នកមិនអាចចម្លងរោគតាមរយៈ៖



ការឱប ឬការថើប



ការបរិភោគអាហារ និងការប្រើប្រដាប់ប្រដាបរិភោគរួមគ្នា



ការបរិភោគអាហារដែលរៀបចំដោយនរណាម្នាក់ដែលមានជំងឺរលាកថ្លើមប្រភេទ B



សត្វល្អិត ឬសត្វទិចខាំ ដែលរួមមានមូស



ការប្រើបន្ទប់ទឹក ក្បាលទឹកផ្កាឈូក ឬបង្គន់រួមគ្នា



ការក្អក ឬកណ្តាស់

បើសិន អ្នកមានផ្ទៃពោះ ហើយមានជំងឺរលាកថ្លើមប្រភេទ B នោះ ទារករបស់អ្នកគួរចាក់ថ្នាំបង្ការរោគនៅក្នុងរយៈពេល 12 ម៉ោងបន្ទាប់ពីបានកើតមក។ ការចាក់ថ្នាំបង្ការរោគនេះ មានផ្ទុក អង្គបដិប្រាណនៅក្នុងឈាមដើម្បីការពារប្រឆាំងមេរោគសម្រាប់ជំងឺរលាកថ្លើមប្រភេទ B ដែលជាអង្គបដិប្រាណជួយប្រព័ន្ធភាពស៊ាំនឹងជំងឺប្រឆាំងនឹងមេរោគ។ ការចាក់ថ្នាំបង្ការរោគនេះ រួមជាមួយវគ្គចាក់ថ្នាំបង្ការរោគសម្រាប់ជំងឺរលាកថ្លើមប្រភេទ B ដែលចាប់ផ្តើមតាមពេលវេលាដូចគ្នាគឺមានប្រសិទ្ធភាពខ្ពស់ក្នុងការការពារទារកប្រឆាំងនឹងជំងឺរលាកថ្លើមប្រភេទ B។ ស្ត្រីមួយចំនួនក៏អាចទទួលបានអត្ថប្រយោជន៍ផងដែរពីការព្យាបាលនៅអំឡុងពេលមានផ្ទៃពោះ ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងវីរុសទៅកូនរបស់ពួកគេ។[5]

## 6

# បរិភោគអាហារដែលមានសុខភាពល្អ ហាត់ប្រាណនិងកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងនិងការជក់បារី៣



វាមានសារៈសំខាន់ផងដែរ ដើម្បីថែរក្សារាងកាយរបស់អ្នក ការបរិភោគអាហារដែលមានសុខភាពល្អ ការហាត់ប្រាណ និងការចៀសវាងប្រើប្រាស់គ្រឿងស្រវឹង និងការជក់បារី

គ្រឿងស្រវឹង បារី និងការលើសទម្ងន់ ធ្វើឱ្យខូចថ្លើមរបស់អ្នក ដែលអាក្រក់ជាពិសេស បើសិន អ្នកមានជំងឺរលាកថ្លើមប្រភេទ B ដោយសារតែវីរុសអាចធ្វើឱ្យខូចថ្លើមរបស់អ្នកផងដែរ។ បើសិន អ្នកត្រូវការជំនួយដើម្បីផ្លាស់ប្តូររបបអាហាររបស់អ្នក ឬកាត់បន្ថយការប្រើគ្រឿងស្រវឹង និងការជក់បារី អ្នកគួរពិគ្រោះយោបល់ជាមួយគ្រូពេទ្យរបស់អ្នក។[6]

អ្នកគួរពិគ្រោះយោបល់ជាមួយគ្រូពេទ្យរបស់អ្នកផងដែរអំពីការប្រើថ្នាំពេទ្យ ឬថ្នាំបំប៉នបន្ថែមណាមួយដែល អ្នកប្រើ រួមមានឱសថបុរាណ និងថ្នាំចិនបុរាណ ដោយសារ ថ្នាំមួយចំនួនអាចបង្កបញ្ហាអាក្រក់ដល់ថ្លើមរបស់អ្នក បើសិនអ្នកមានជំងឺរលាកថ្លើមប្រភេទ B។[7]

## 7

# សូមទៅជួបគ្រូពេទ្យរបស់អ្នកជាប្រចាំ

វាមានសារៈសំខាន់ណាស់ដែល អ្នកត្រូវទៅជួបគ្រូពេទ្យរបស់អ្នករៀងរាល់ប្រាំមួយខែម្តង ឬតាមការណែនាំដើម្បីពិនិត្យមើល បើសិនមានការខូចខាតថ្លើមណាមួយ។ អ្នកដែលមានជំងឺរលាកថ្លើមប្រភេទ B ជាញឹកញាប់មិនមានសញ្ញា ឬរោគសញ្ញាណាមួយឡើយ។ បើសិនអ្នករង់ចាំរហូតដល់អ្នកមានអារម្មណ៍ថាឈឺនោះ វីរុសនេះអាចបណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងខ្លាំង ដែលអាចមិនវិលត្រឡប់មកស្ថានភាពដើមវិញបានទេ។ វិធីតែមួយគត់ ដើម្បីដឹងពីបញ្ហានេះ ត្រូវពិនិត្យមើលថ្លើមឱ្យបានទៀងទាត់។[5]

បើសិនវីរុសចាប់ផ្តើមបង្កការខូចខាតដល់ថ្លើមរបស់អ្នក មានថ្នាំដែល អ្នកអាចប្រើដើម្បីគ្រប់គ្រងនិងកាត់បន្ថយផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់ពីវីរុសនេះ។

អ្នកអាចត្រូវការទៅជួបគ្រូពេទ្យញឹកញាប់ថែមទៀត បើសិនមានការណែនាំ ជាពិសេសក្នុងឆ្នាំដំបូងនៃការព្យាបាល។

### តើអ្នកបានដឹងទេ ?



ថ្លើមមិនមានសរសៃឈាមណាមួយដែលមានអារម្មណ៍ថាឈឺចាប់នោះ។ មានកន្សោម (ឬថង់) នៃជាលិកានៅជុំវិញថ្លើម ដែលអាចមានអារម្មណ៍ឈឺចាប់ បើសិនថ្លើមលាតសន្ធឹង។ ហើយនេះជាមូលហេតុដែល អ្នកមិនមានរោគសញ្ញាណាមួយពីជំងឺរលាកថ្លើមប្រភេទ B រហូតដល់ថ្លើមរបស់អ្នកខូចខាតធ្ងន់ធ្ងរ។[8]



# 8 ទទួលការព្យាបាល បើសិនចាំបាច់

មិនមែនមនុស្សគ្រប់រូបដែលមានជំងឺរលាកថ្លើមប្រភេទ B ត្រូវការព្យាបាលទេ ដោយសារតែវីរុសនេះឆ្លងកាត់ដំណាក់កាលផ្សេងគ្នា។ ក្នុងដំណាក់កាលខ្លះ វីរុសអាចសកម្មយ៉ាងខ្លាំង និងបង្កឱ្យមានរបួសដល់ថ្លើមរបស់អ្នក។ នៅពេល អ្នកទៅជួបគ្រូពេទ្យរបស់អ្នក ដើម្បីពិនិត្យមើលថ្លើម ពួកគេអាចដឹងថាតើវីរុសនេះសកម្មយ៉ាងណា ដោយការធ្វើតេស្តឈាម ហើយថាតើអ្នកត្រូវការចាប់ផ្ដើមព្យាបាលឬអត់។[5]

## ដំណាក់កាលនៃជំងឺរលាកថ្លើមប្រភេទ B

| | | | |
|---|---|---|---|
| ស្ងៀមស្ងាត់ | ដំណាក់កាល 1 | ការអត់ឱនភាពស៊ាំនឹងជំងឺ | វីរុសជំងឺរលាកថ្លើមប្រភេទ B កំពុងចម្លងខ្លួនវា ប៉ុន្តែមិនមានសកម្មភាពការខូចខាតថ្លើម ទេ។ |
| ការខូចខាត | ដំណាក់កាល 2 | ក្លួរបោសសម្អាតភាពស៊ាំនឹងជំងឺ | វីរុសជំងឺរលាកថ្លើមប្រភេទ B កំពុងវាយលុកប្រព័ន្ធភាពស៊ាំនឹងជំងឺ ហើយប្រព័ន្ធភាពនឹងស៊ាំជំងឺកំពុងប្រយុទ្ធប្រឆាំងតបវិញ។ ថ្លើមកំពុងទទួលរងការខូចខាត។ |
| ការគ្រប់គ្រង | ដំណាក់កាល 3 | ការគ្រប់គ្រងភាពស៊ាំនឹងជំងឺ | ប្រព័ន្ធភាពស៊ាំនឹងជំងឺមានវីរុសស្ថិតនៅក្រោមការគ្រប់គ្រង ហើយមិនមានការខូចខាតថ្លើមថែមទៀតទេ។ |
| ការគេចវេះ | ដំណាក់កាល 4 | ការគេចវេះភាពស៊ាំនឹងជំងឺ | វីរុសសកម្មម្តងទៀត ហើយថ្លើមទទួលរងការខូចខាត។ |

ការប្រើថ្នាំទូទៅច្រើនបំផុតសម្រាប់ព្យាបាលជំងឺរលាកថ្លើមប្រភេទ B គឺថ្នាំប្រឆាំងនឹងវីរុសដែល អ្នកលេបរាល់ថ្ងៃសម្រាប់រយៈពេលមួយឆ្នាំ ឬយូរជាងនេះ ដូចដែលបានណែនាំដោយគ្រូពេទ្យអ្នក។

បើសិនអ្នកត្រូវការព្យាបាលជំងឺរលាកថ្លើមប្រភេទ B អ្នកអាចត្រូវទៅជួបគ្រូពេទ្យជំនាញណាម្នាក់ លុះត្រាតែគ្រូពេទ្យ GP របស់អ្នកមានបទពិសោធន៍ជាមួយនឹងការព្យាបាលជំងឺរលាកថ្លើមប្រភេទ B។ គ្រូពេទ្យ GP របស់អ្នក នឹងផ្តល់ជូនអ្នកនូវការបញ្ជូនទៅអ្នកជំនាញថ្លើម បើសិនត្រូវការចាំបាច់។[9]

ឯកសារយោង៖ : 1. ASHM. (2012, September). Hepatitis B and Primary Care Providers. Retrieved from ASHM. 2. ASHM. (2016, March). Indications for HBV testing. Retrieved from ASHM 3. Department of Home Affairs. (n.d.). TIS National. Retrieved from www.tisnational.gov.au/ 4. Hepatitis NSW. (2018, May 11). Hep B testing for adults. Retrieved from Hepatitis NSW. 5. ASHM. (2019). Hepatitis B. Retrieved from All good. 6. Hepatitis Queensland. (2019). Living with Hepatitis. Retrieved from Hepatitis Queensland. 7. hep. (2019, March 4). Natural Remedies and Hepatitis B. Retrieved from hepmag. 8. Stöppler, M. (2017, January 24). Medical Definition of Liver Pain. Retrieved from MedicineNet. 9. Hep B Help. (2019). New HBV Diagnosis – what now? Retrieved from Hep B Help.